**នៅចំពោះមុខអង្គជំនុំជម្រះសាលាដំបូង**
**នៃអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា**

**ព័ត៌មានលម្អិតនៃការដាក់ឯកសារ**

សំណុំរឿងលេខ : ០០២/១៩-០៩-២០០៧-អវតក/អជសដ
ដាក់ទៅ : អង្គជំនុំជម្រះសាលាដំបូង
ថ្ងៃដាក់ : ថ្ងៃទី២១ ខែឧសភា ឆ្នាំ២០១៣
ភាគីអ្នកដាក់ : សហព្រះរាជអាជ្ញា
ភាសាដើម : អង់គ្លេស


**ឯកសារបកប្រែ**
**TRANSLATION/TRADUCTION**
ថ្ងៃ ខែ ឆ្នាំ (Date): 21-May-2013, 13:00
CMS/CFO: Sann Rada


**ចំណាត់ថ្នាក់ឯកសារ**

ប្រភេទឯកសារដែលស្នើឡើងដោយភាគីដាក់ឯកសារ: **សាធារណៈ**
ចំណាត់ថ្នាក់ឯកសារកំណត់ដោយអង្គជំនុំជម្រះ: សាធារណៈ/Public
ប្រភេទនៃចំណាត់ថ្នាក់ឯកសារ:
ការពិនិត្យឯកសារបណ្ដោះអាសន្នឡើងវិញ:
ឈ្មោះមន្ត្រីដែលបានពិនិត្យ:
ហត្ថលេខា:

---

# សំណើរបស់សហព្រះរាជអាជ្ញាសុំឲ្យមានការផ្លាស់ប្ដូរព័ត៌មាននៅមុនពេល ការប្រជុំរៀបចំសវនាការនាពេលខាងមុខនេះ

---

**អ្នកដាក់ឯកសារ:**
**សហព្រះរាជអាជ្ញា**
លោកស្រី ជា លាង
លោក Andrew CAYLEY

**អ្នកទទួលឯកសារ:**
**អង្គជំនុំជម្រះសាលាដំបូង**
ចៅក្រម និល ណុន, ប្រធាន
ចៅក្រម Silvia CARTWRIGHT
ចៅក្រម យ៉ា សុខន
ចៅក្រម Jean-Marc LAVERGNE
ចៅក្រម យូ ឧត្តរា

**សហមេធាវីនាំមុខតំណាងដើមបណ្ដឹងរដ្ឋប្បវេណី:**
លោក ពេជ អង្គ
លោកស្រី Elisabeth SIMONNEAU FORT

**ចម្លងជូន:**
**ជនជាប់ចោទ**
នួន ជា
ខៀវ សំផន

**មេធាវីការពារក្ដីជនជាប់ចោទ:**
លោក សុន អរុណ
លោក Victor KOPPE
លោក គង់ សំអុន
លោក Jacques VERGÈS
លោក Arthur VERCKEN
លោកស្រី Anta GUISSE

# សំណើ

១. នៅថ្ងៃទី៨ ខែឧសភា ឆ្នាំ២០១៣ មេធាវីការពារក្តី ខៀវ សំផនបានស្នើសុំអង្គជំនុំជម្រះសាលាដំបូងឱ្យធ្វើការកោះប្រជុំរៀបចំសវនាការមួយ "ដើម្បីស្តាប់ហេតុផលរបស់ភាគីជាមុនសិន មុនពេលអង្គជំនុំជម្រះសម្រេច កំណត់ប្រក្រតិទិនសវនាការដែលនៅសេសសល់ ត្រូវធ្វើក្នុងក្របខណ្ឌនៃសំណុំរឿងលេខ០០២/០១"[1]។ នៅថ្ងៃទី១៦ ខែឧសភា ឆ្នាំ២០១៣ មន្ត្រីច្បាប់របស់អង្គជំនុំជម្រះសាលាដំបូង លោក Matteo Crippa បានជូនដំណឹងដល់ភាគីនានា តាមរយៈអ៊ីមែលថា អង្គជំនុំជម្រះសាលាដំបូង មានបំណងនឹងចាត់កាលវិភាគសម្រាប់ធ្វើការប្រជុំ រៀបចំសវនាការ។ អ៊ីមែលនោះបានថ្លែងថា "ទាក់ទងទៅនឹងសំណើនាពេលថ្មីៗនេះ ដែលអង្គជំនុំជម្រះសាលាដំបូងបានទទួល និង កាលវិភាគបច្ចុប្បន្ន ស្តីពីកិច្ចដំណើរការនីតិវិធីសវនាការ ចៅក្រមទាំងឡាយនៃអង្គជំនុំជម្រះសាលាដំបូង បានអនុញ្ញាតឱ្យខ្ញុំជូនដំណឹងដល់អស់លោក-លោកស្រីថា ក្នុងពេលឆាប់ៗនេះ អង្គជំនុំជម្រះ នឹងចាត់កាលវិភាគសវនាការមួយ ដើម្បីពិភាក្សាអំពីបញ្ហានៅមិនទាន់បានដោះស្រាយនានា ដែលមានជាប់ទាក់ទងទៅនឹងការសេសសល់ នៃសវនាការ០០២/០១។ ដូចជា ការអនុវត្តពីមុនៗរបស់អង្គជំនុំជម្រះ ដូច្នោះដែរ របៀបវារៈមួយដែលជាការស្នង់ស្នើ នឹងត្រូវបានផ្ញើចែកជូនជាមុនឱ្យដល់គ្រប់ភាគីទាំងអស់"។

២. សហព្រះរាជអាជ្ញា សូមស្វាគមឱកាសនេះ ដើម្បីឱ្យបានស្តាប់ពីបញ្ហានានាដែលនៅមិនទាន់បានដោះស្រាយ ដើម្បីបញ្ចប់សវនាការនេះ។ ដើម្បីជួយដល់អង្គជំនុំជម្រះសាលាដំបូង ក្នុងការធ្វើការប្រជុំរៀបចំសវនាការនេះឱ្យមានប្រសិទ្ធិភាពតាមដែលអាចធ្វើទៅបាន សហព្រះរាជអាជ្ញា សូមស្នើដោយគោរពថា នៅមុនពេលមានការប្រជុំនេះចំនួនមួយសប្តាហ៍ សូមឱ្យអង្គជំនុំជម្រះសាលាដំបូងផ្តល់ជូនដល់ភាគីនានានូវព័ត៌មានទាំងឡាយដូចតទៅនេះ៖

ក. បញ្ជីសាក្សី អ្នកជំនាញ និងដើមបណ្តឹងរដ្ឋប្បវេណី ដែលអង្គជំនុះជម្រះសាលាដំបូងមានបំណងចង់ធ្វើការកោះហៅ នៅមុនពេល <u>ធ្វើសេចក្តីសន្និដ្ឋានបិទដំណើរការនីតិវិធីដេញដោលលើភស្តុ</u>

[1] **E284/1** សំណើសុំឱ្យមានកិច្ចប្រជុំរៀបចំសវនាការដើម្បីកំណត់ប្រក្រតិទិនច្បាស់លាស់មួយសម្រាប់ដំណាក់កាលសវនាការដែលនៅសេសសល់ក្នុងសំណុំរឿង ០០២/០១, ៨ ឧសភា ២០១៣។

តាង (ក្រៅពីអ្នកទាំងឡាយដែលបានកំណត់កាលវិភាគរួចរហូតដល់ និងដែលក្នុងនោះរួមបញ្ចូលទាំងថ្ងៃទី៤ ខែមិថុនា ឆ្នាំ២០១៣ ផង)។

ខ. បញ្ជីឯកសារ សម្រាប់សវនាការដេញដោលណាមួយបន្ថែមទៀត ដែលអង្គជំនុំជម្រះសាលាដំបូងមានបំណងចង់បើកធ្វើ(ជាបន្ថែមពីលើសវនាការ ស្ដីពីការបង្ហាញឯកសារដែលត្រូវបានប្រកាសជូនដំណឹងស្ដីពីតួនាទីរបស់ នួន ជា និង ស្ដីពីគោលនយោបាយសហកម្មឧក្រិដ្ឋកម្មរួមចំនួនប្រាំ)។

គ. បញ្ជីនៃសវនាការដេញដោលលើឯកសារណាមួយផ្សេងទៀត លើបញ្ហានានាដែលនៅសេសសល់។

ឃ. តារាងកាលវិភាគមួយចាប់ពីថ្ងៃទី៤ ខែមិថុនា ឆ្នាំ២០១៣ រហូតដល់ពេលចប់សវនាការដេញដោលលើភស្តុតាង ដែលរួមបញ្ចូលទាំងការសម្រាកដែលបានធ្វើផែនការរួចផង។

ង. តារាងកាលវិភាគសម្រាប់ការបិទការដេញដោលផ្ទាល់មាត់នៅក្នុងសវនាការនេះ។ ដែលរួមបញ្ចូលទាំងការ បែងចែកពេលវេលាដល់ភាគីនានាសម្រាប់សារណាផ្ទាល់មាត់ និងចម្លើយតបរបស់ពួកគេផង។

៣. សូមស្នើបន្ថែមថា <u>គួរបានអញ្ជើញភាគីនានាឲ្យដាក់សារណារបស់ខ្លួនលើកាលវិភាគចុងក្រោយរបស់អង្គជំនុំជម្រះសាលាដំបូង</u> បន្ទាប់ពីបានទទួលព័ត៌មានដូចដែលបានលើកយោងនៅក្នុង កថាខណ្ឌទី២ និងយ៉ាងហោចណាស់ ឲ្យបានបីថ្ងៃមុនពេលប្រជុំស្ដីពីការរៀបចំសវនាការ។ សារណានិងសេចក្ដីសង្កេតបែបនេះ គួរបានដាក់បញ្ចូលនូវបញ្ជីសាក្សី អ្នកជំនាញ និងដើមបណ្ដឹងរដ្ឋប្បវេណី ក៏ដូចជា ឯកសារ និងសវនាការផ្សេងទៀតដែលភាគីនានា បានស្នើសុំបន្ថែមពីលើបញ្ជី និងឯកសារដែលបានជូនដំណឹង ដោយអង្គជំនុំជម្រះសាលាដំបូង។ សារណាគួរត្រូវបានធ្វើការអញ្ជើញតាមកាលវិភាគ ហើយនិងរយៈពេលរបស់សវនាការបិទការពិភាក្សាដេញដោលដោយផ្ទាល់មាត់ ទៅតាមការចាំបាច់។

៤. សូមផ្តល់នូវការសន្និដ្ឋានដោយគោរពថា ការស្នើសុំផ្លាស់ប្តូរព័ត៌មានដ៏សំខាន់ពីគ្នាទៅវិញទៅមករវាងអង្គជំនុំជម្រះសាលាដំបូងនិងគូភាគីនៅមុនពេលកិច្ចប្រជុំរៀបចំសវនាការ នឹងជួយបានយ៉ាងសំខាន់ដល់អង្គជំនុំជម្រះ នៅក្នុងការដោះស្រាយឱ្យបានទាន់ពេលវេលាលើគ្រប់បញ្ហាទាំងអស់ដែលពាក់ព័ន្ធទៅនឹងការបញ្ចប់កិច្ចដំណើរការនីតិវិធីលើភ័ស្តុតាង។ ការណ៍នេះក៏នឹងអនុញ្ញាតឱ្យគូភាគីបានបំពេញនូវតួនាទី និងកាតព្វកិច្ចរបស់ខ្លួនទាក់ទិននឹងចំណុចនេះផងដែរ។

| កាលបរិច្ឆេទ | ឈ្មោះ | ទីកន្លែង | ហត្ថលេខា |
|---|---|---|---|
| ថ្ងៃទី២១ ខែឧសភា ឆ្នាំ២០១៣ | **លោកស្រី ជា លាង**<br>សហព្រះរាជអាជ្ញា | ភ្នំពេញ | |
| | **លោក Andrew CAYLEY**<br>សហព្រះរាជអាជ្ញា | | |